អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

**អង្គភាពគាំពារជនរងគ្រោះ**
Victims Support Section
Section d'appui aux victimes

**ភ្នំពេញ ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០១០**

# សេចក្តីប្រកាសព័ត៌មាន

## អង្គភាពគាំពារជនរងគ្រោះរៀបចំវគ្គបណ្តុះបណ្តាលដល់ជនបង្គោលតាមបណ្តាខេត្តចំនួន២១ ដើម្បីសម្រួលការងារផ្តល់ព័ត៌មានដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២

អង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងរៀបចំវគ្គបណ្តុះបណ្តាលដល់ជនបង្គោលបន្ថែមទៀតចំនួន ១២០នាក់មកពីបណ្តាខេត្ត-ក្រុងចំនួន ២១។ វគ្គបណ្តុះបណ្តាលនេះនឹងប្រព្រឹត្តិទៅនៅ **ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១០ នៅសណ្ឋាគារអឹមភីរៀល ហ្គាដិន វីឡា រាជធានីភ្នំពេញ ចាប់ពីម៉ោង ៨ ព្រឹក**។

វគ្គបណ្តុះបណ្តាលនេះ ធ្វើឡើងក្នុងគោលបំណងផ្តល់ឱកាសឲ្យជនបង្គោលដែលបានជ្រើសរើសទាំងអស់នោះបានទទួលការរៀនសូត្រពីរបៀបទទួល និងផ្តល់ព័ត៌មានបន្តពីអង្គភាពគាំពារជនរងគ្រោះឲ្យបានត្រឹមត្រូវ និងទាន់ពេលវេលាសម្រាប់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២។ កម្មវិធីនេះក៏ផ្តល់ឱកាសផងដែរដល់ជនបង្គោលទាំងនោះបានជួបជាមួយនឹងមន្ត្រីមកពីការិយាល័យនានានៃ អ.វ.ត.ក និងបុគ្គលិកអង្គការសង្គមស៊ីវិល ដើម្បីស្វែងយល់ពីកិច្ចការផ្សេងៗដែលទាក់ទិននឹងសិទ្ធិ ករណីកិច្ចរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងធានាឲ្យជនបង្គោលទាំងនោះអាចរៀបចំការបណ្តុះបណ្តាលបន្តដល់ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងៗជាច្រើនទៀត ដែលមានទីលំនៅ នៅឆ្ងាយពីរាជធានីភ្នំពេញ និងបណ្តាខេត្តនានា។

សូមរំលឹកផងដែរថា កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១០ កន្លងទៅ អង្គភាពគាំពារជនរងគ្រោះក៏បានរៀបចំវគ្គបណ្តុះបណ្តាលដល់ជនបង្គោលមកពីបណ្តាលខេត្តចំនួន ១៨ ដើម្បីសម្រួលការងារផ្តល់ព័ត៌មានដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ នៅសណ្ឋាគារសាន់វេ ប្រកបដោយជោគជ័យរួចមកហើយ។


**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមក៖**

1. លោក **អ៊ឹម សុភា** ប្រធានកម្មវិធីផ្សព្វផ្សាយ, ទូរស័ព្ទ 077 777 367, im.sophea@eccc.gov.kh